**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ៤៤៣៤ សហវ....

ថ្ងៃសុក្រ ១១កើត ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ ២០១៨

**គោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**កម្មវត្ថុ:** ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យា ស្តីពីការងារស្ថាបនាស្ពានបេតុងចំនួន ០១កន្លែង ប្រវែង ៣៦ម ទទឹង ៨ម និងស្ថាបនាផ្លូវសងខាងក្បាលស្ពានប្រវែង ២០០ម ស្ថិតនៅឃុំខ្យង ស្រុកជ័យសែន ខេត្តព្រះវិហារ។

**យោង:** - លិខិតលេខ ១៩៥៦ សហវ.អថ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កំណត់ហេតុចរចាថ្លៃ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៨ របស់ គ.ល ក្រសួងអភិវឌ្ឍន៍ជនបទ
- លិខិតលេខ ០៦៨៥/១៨ ក.អ.ជ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការប្រគល់កិច្ចសន្យា ជូនបញ្ជាការដ្ឋានវិស្វកម្មកងទ័ពជើងគោក ដើម្បីធ្វើការងារស្ថាបនាស្ពានបេតុងចំនួន ០១កន្លែង ប្រវែង ៣៦ម ទទឹង ៨ម និងស្ថាបនាផ្លូវសងខាងក្បាលស្ពានប្រវែង ២០០ម ស្ថិតនៅភូមិខ្យង និងភូមិស្លែង ឃុំខ្យង ស្រុកជ័យសែន ខេត្តព្រះវិហារ ក្នុងតម្លៃសរុបចំនួន ១ ៧០៣ ០០០ ០០០រៀល (មួយប៊ីលាន ប្រាំពីររយបីលានរៀលគត់) ជាតម្លៃកិច្ចសន្យា។

ការជួលបន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ជាដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបាន ត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាប និងមានវិធានការអនុវត្តបន្តឱ្យបានសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**ជ. ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**រដ្ឋលេខាធិការ**

**ជួ និរិត្ថ**

**ចម្លងជូន:**
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតី
តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
-អគ្គនាយកដ្ឋានថវិកា
-អគ្គនាយដ្ឋានរតនាគារជាតិ
-បញ្ជាការដ្ឋានវិស្វកម្មកងទ័ពជើងគោក
-សាលាខេត្តព្រះវិហារ
-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តព្រះវិហារ
-មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ
-នាយកដ្ឋានផ្លូវលំជនបទ
-ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798